Save the Mekong
Our River Feeds Millions

# សម្ព័ន្ធសង្គ្រោះទន្លេមេគង្គ

# ទន្លេរបស់យើង ចិញ្ចឹមប្រជាជនរាប់លាននាក់

# សេចក្តីថ្លែងការណ៍ឈាងខុង ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០១៧

ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០១៧ ជាទិវាអន្តរជាតិនៃសកម្មភាពដើម្បីទន្លេ យើងខ្ញុំទាំងអស់គ្នាជាសម្ព័ន្ធសង្គ្រោះទន្លេមេគង្គ រួមជាមួយដៃគូសង្គមស៊ីវិល និងសហគមន៍ មកពីប្រទេសថៃ ប្រទេសកម្ពុជា និងប្រទេសវៀតណាម ចេញសេចក្តីថ្លែងការណ៍នេះ ដើម្បីសម្តែងការដឹងគុណចំពោះទន្លេមេគង្គ និងរបៀបនៃការរស់នៅដែលពឹងអាស្រ័យលើទន្លេ។ ទន្លេមេគង្គ គឺជាទន្លេម្តាយ ជាជម្រកនៃជីវចម្រុះតែមួយគត់ និងជាសរសៃឈាមនៃជីវិតមនុស្សរាប់លាននាក់ ដែលរស់នៅក្នុងអាងទន្លេនេះ។ យើងខ្ញុំទទួលស្គាល់កិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ទន្លេមេគង្គ ដែលបានខិតខំការពារ និងអភិរក្សប្រព័ន្ធអេកូឡូស៊ី និងធនធាននានានៅក្នុងទន្លេនេះ សម្រាប់មនុស្សជំនាន់ក្រោយ។

យើងខ្ញុំទាំងអស់គ្នា មានក្តីកង្វល់យ៉ាងក្រៃលែង ពីគម្រោងអភិវឌ្ឍន៍ខ្នាតធំនានា ដែលមិនបានទទួលស្គាល់ពីចំណេះដឹង វប្បធម៌ និងសម្លេងរបស់ស្ត្រី និងបុរស ដែលរស់នៅតាមសហគមន៍នៅក្នុងអាងទន្លេមេគង្គ ដែលជីវិត និងជំនឿនានារបស់ពួកគេ ពាក់ព័ន្ធយ៉ាងជិតស្និតនឹងទន្លេមេគង្គ។ ការធ្វើផែនការ នងការសម្រេចចិត្តស្តីពីទំនប់វារីអគ្គិសនី និងគម្រោងនានា នៅលើដងទន្លេមេគង្គ ខ្វះការចូលរួមជាសាធារណៈ ខ្វះតម្លាភាព និងភាពទទួលខុសត្រូវ។

ទន្លេ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការទ្រទ្រង់ការរស់រានមានជីវិតរបស់មនុស្សនៅលើពិភពលោក ប៉ុន្តែ នៅគ្រប់ទីកន្លែង ប្រព័ន្ធទឹកសាប កំពុងត្រូវបានបំផ្លាញ និងធ្វើឲ្យខូចខាត។ ខណៈពេលមានការប្រែប្រួលអាកាសធាតុ និងការកើនឡើងនៃកង្វះទឹកនោះ វាកាន់តែចាំបាច់ខ្លាំងជាងមុនបន្ថែមទៀត ក្នុងការការពារធនធាន ក៏ដូចជាជីវចម្រុះ ប្រព័ន្ធបែបធម្មជាតិដែលមានសារៈសំខាន់ទាំងនេះ ព្រមទាំងវប្បធម៌នៃការរស់នៅដែលគាំទ្រដោយទន្លេ។

នៅក្នុងទិវានេះ ប្រជាជននៅតាមសហគមន៍រាប់រយនាក់ នៅជុំវិញពិភពលោក កំពុងតែរួបរួមគ្នាដើម្បីធ្វើសកម្មភាពសម្រាប់ទន្លេរបស់ពួកគេ។ យើងខ្ញុំទាំងអស់គ្នា ចូលរួមក្នុងសាមគ្គីភាពជាមួយសហគមន៍ទាំងអស់នៅតាមដងទន្លេមេគង្គ។ យើងខ្ញុំប្រកាសជាថ្មីម្តងទៀត នូវការប្តេជ្ញាចិត្តរបស់យើងខ្ញុំ ដើម្បីធ្វើការរួមគ្នា នៅទូទាំងអាងទន្លេមេគង្គ ដោយផ្តល់អាទិភាពដល់សម្លេងរបស់សហគមន៍នៅក្នុងអាងទន្លេមេគង្គ នៅក្នុងការធ្វើសេចក្តី សម្រេចចិត្ត លើអនាគតនៃទន្លេមេគង្គ សម្រាប់មនុស្សជំនាន់នេះ និងជំនាន់ក្រោយៗទៀត។